ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ០៥ប្រក

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០

នៅព្រឹកថ្ងៃសុក្រ ១៣កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ។
២-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។
៣-បញ្ហាផ្សេងៗ៖
សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋកូរ៉េ។

ក្រោយពីបានស្តាប់របាយការណ៍និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

១-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ត្រូវបានរៀបចំឡើងដោយផ្អែកលើមាត្រា៥៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ដែលចែងថា៖ "ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថាជារបស់រដ្ឋ។ ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវកំណត់ក្នុងច្បាប់"។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានរៀបចំឡើងដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ រចនាសម្ព័ន្ធស្ថាប័ន និងលើកកម្ពស់សមត្ថភាពស្ថាប័នក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាអាទិ៍ ការកំណត់អំប្រែភព ប្រភេទទ្រព្យសម្បត្តិរដ្ឋ របបគតិយុត្តគ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិរដ្ឋច្បាស់លាស់ជាក់លាក់ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ការផ្ទេរសិទ្ធិកាន់កាប់ ការអភិរក្ស ការអភិវឌ្ឍ ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ការធ្វើអធិការកិច្ចនិងសវនកម្ម និងការកំណត់អំពីការលើកទឹកចិត្ត និងការដាក់ទណ្ឌកម្មចំពោះអំពើល្មើសច្បាប់នានាជាដើម។

សេចក្តីព្រាងច្បាប់នេះ មានគោលបំណងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងអភិបាលកិច្ចល្អ បង្កើនប្រសិទ្ធភាព តម្លាភាព សក្តិសិទ្ធិភាព និងគណនេយ្យភាពនៃការគ្រប់គ្រងការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីជាឧត្តមប្រយោជន៍ជាតិនិងប្រជាជន រួមចំណែកឈានទៅសម្រេចគោលដៅនៃចក្ខុវិស័យឆ្នាំ២០៣០ ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ ២០៥០។

សេចក្តីព្រាងច្បាប់នេះរៀបចំឡើងមានចំនួន១២ជំពូកនិង៩០មាត្រា ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

២-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការរក្សាស្ថិរភាពនយោបាយ លើកកម្ពស់សន្តិសុខ និងការកសាងហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ចជាតិ បានផ្តល់អំណោយផលដល់ការកើនឡើងជាលំដាប់នូវវិនិយោគិនជាតិនិងអន្តរជាតិចូលមកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយក្នុងនោះក៏មានការវិនិយោគលើវិស័យកាស៊ីណូផងដែរ។

អាជីវកម្មកាស៊ីណូ បានចូលរួម៖

ទី១- ជំរុញការអភិវឌ្ឍតំបន់ព្រំដែនដែលជាតំបន់អតីតសមរភូមិ តំបន់ពោរពេញទៅដោយគ្រាប់មីន តំបន់គ្រុនចាញ់ តំបន់គ្មានការអភិវឌ្ឍនិងគ្មានប្រជាជនរស់នៅ។

ទី២- ការពារខ្សែក្រវាត់ព្រំដែន តាមរយៈការសាងសង់អគារដ៏រឹងមាំ មានលក្ខណៈយូរអង្វែង និងការលើកទឹកចិត្តការមកតាំងទីលំនៅថ្មីរបស់ប្រជាជន។

ទី៣- គាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍និងការបង្កើតការងារជូនប្រជាពលរដ្ឋ។

ទី៤- បង្កើតប្រភពចំណូលថវិកាជាតិ។

មកដល់បច្ចុប្បន្ននេះ ប្រទេសជាច្រើននៅលើពិភពលោកបានប្រែក្លាយល្បែងពាណិជ្ជកម្មទៅជាមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ (Integrated Resort) និងជាកន្លែងកម្សាន្តទាក់ទាញទេសចរជាច្រើនតាមរយៈការរៀបចំទីតាំងល្បែងពាណិជ្ជកម្មដោយរួមបញ្ចូលនូវទីតាំងបដិសណ្ឋារកិច្ច ភោជនីយដ្ឋានផ្សារទំនើប សណ្ឋាគារ មណ្ឌលកីឡា មណ្ឌលកម្សាន្តនិងទស្សនា មណ្ឌលសន្និបាតឬពិព័រណ៌ និងហាងលក់ទំនិញរួចពន្ធជាដើម គឺជាប្រភពចំណូលថវិកាដ៏សំខាន់ និងជាទីតាំងបង្កើតការងារជាច្រើនប្រភេទនៃឧស្សាហកម្មគ្មានផ្សែង ព្រមទាំងបានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច។

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្មនេះ ត្រូវបានតាក់តែងឡើងក្នុងគោលបំណងធានាដល់ការគ្រប់គ្រងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ និងល្បែងពាណិជ្ជកម្ម ដើម្បីរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច លើកកម្ពស់វិស័យទេសចរណ៍ បង្កើតការងារ ប្រមូលចំណូលចូលរក្សាសុវត្ថិភាព និងសន្តិសុខសង្គម ដែលជាទស្សនទានមួយថ្មីនៃការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

សេចក្តីព្រាងច្បាប់នេះនឹងអនុញ្ញាតឱ្យមានការគ្រប់គ្រងលើវិស័យកាស៊ីណូនិងល្បែងពាណិជ្ជកម្ម ដទៃទៀតយ៉ាងតឹងរឹងនិងប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមរយៈការកំណត់ចំនួនទុនវិនិយោគអប្បបរមា សម្រាប់អាជីវកម្មកាស៊ីណូ ការកំណត់តំបន់ដែលគួរអនុញ្ញាតឱ្យមានល្បែងពាណិជ្ជកម្ម ឬមិនគួរអនុញ្ញាត ការពង្រឹងសមត្ថភាពស្ថាប័ន និងការបំពាក់នូវបច្ចេកវិទ្យាសមស្របក្នុងការត្រួតពិនិត្យជាប្រចាំលើកិច្ចដំណើរការ របស់ប្រតិបត្តិករល្បែងពាណិជ្ជកម្ម ព្រមទាំងបានគិតគូរផងដែរអំពីយន្តការយ៉ាងតឹងរឹងពាក់ព័ន្ធនឹងការ ប្រឆាំងការលាងសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

សេចក្តីព្រាងច្បាប់នេះរៀបចំឡើងមាន១២ជំពូកនិង៩៧មាត្រា ហើយត្រូវបានសម្រេចឯកភាព ដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

៣-បញ្ហាផ្សេងៗ៖

កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសម្រេចឯកភាពបញ្ជូន សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រម លើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉ េដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ។

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានលើកឡើងថា៖

១- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកាត់ឆ្វៀលដីនិងផ្តល់កម្មសិទ្ធិដីជូនដល់ប្រជាពលរដ្ឋ ដែលបានកាន់កាប់និងអាស្រ័យផលជាក់ស្តែងយូរឆ្នាំមកហើយ នៅលើទីតាំងដីដែលស្ថិតនៅក្នុងផែនទីតំបន់ ការពារធម្មជាតិនិងគម្របព្រៃឈើ នៅតាមខេត្តនានាដូចជាកោះកុង ព្រះវិហារ ឧត្តរមានជ័យ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរីជាដើម និងត្រូវបន្ថែមការត្រៀមបម្រុងដី១០% សម្រាប់ការប្រើប្រាស់រួមរបស់ សហគមន៍។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ថា ចំពោះកិច្ចដំណើរការនេះ ត្រូវចុះអនុវត្តដោយផ្ទាល់ ជាក់ស្តែង និងឱ្យបានច្បាស់លាស់។ ទន្ទឹមនឹងនេះ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទប់ស្កាត់ដាច់ខាតកុំឱ្យមានការរុករានទន្ទ្រានដីដោយខុសច្បាប់ ដើម្បីបង្ការ កុំឱ្យក្លាយជាសង្គ្រាមដីធ្លី។

២- ករណីទំនាស់ដីធ្លីនៅស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាល ខេត្តបាត់ដំបង ត្រូវដកហូតត្រឡប់មកវិញនូវដីដែលបុគ្គលឈ្មោះ សង ថន បានទន្ទ្រានរំលោភយកដោយ ខុសច្បាប់ និងត្រូវប្រគល់ឱ្យរដ្ឋបាលខេត្តបាត់ដំបងគ្រប់គ្រងនិងរក្សាទុកសម្រាប់ធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ក្នុងគោលដៅសម្បទានសង្គមកិច្ច។

៣- អង្គភាពប្រឆាំងអំពើពុករលួយត្រូវធ្វើការងារនេះបន្តទៅទៀត។ ដំណាក់កាលនេះ ជាពេល ដែលត្រូវធ្វើការវះកាត់រាល់ជនខិលខូចទាំងឡាយណាដែលឃុបឃិតគ្នាយកដីរដ្ឋនិងដីរបស់ប្រជាពលរដ្ឋ ហើយប្រើកលល្បិចផ្សេងៗ គឺត្រូវផ្តន្ទាទោស ហើយនឹងឈានដល់ការដកហូតមុខតំណែង និងត្រូវ បណ្តេញចេញពីគណបក្សប្រជាជនកម្ពុជាតែម្តង។ ចំពោះបណ្តកម្មសិទ្ធិដីធ្លីទាំងឡាយណាដែលចេញពី អំពើទុច្ចរិត គឺត្រូវធ្វើមោឃភាពចោល។

៤- អនុញ្ញាតឱ្យបើកដំណើរការឡើងវិញបណ្តាកាស៊ីណូនៅភ្នំពេញ(ណាហ្គាវើល) ខេត្តព្រះសីហនុ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ តាមតំបន់ព្រំដែននិងទីតាំងផ្សេងទៀត ដោយឱ្យម្ចាស់កាស៊ីណូត្រូវចុះកិច្ចព្រមព្រៀងឬអនុស្សរណៈជាមួយក្រសួងសុខាភិបាល(ឬមន្ទីរសុខាភិបាល) លើការអនុវត្តតាមវិធានរបស់ក្រសួងសុខាភិបាល ដើម្បីផ្តល់ការងារឱ្យបុគ្គលិកដែលបានបាត់បង់ការងារមួយរយៈកន្លងមក និងជាការជួយឱ្យសេដ្ឋកិច្ចងើបឡើងវិញផងដែរ។

៥- អនុញ្ញាតឱ្យអាជីវកម្មភ្លឺបកម្សាន្ត និង KTV នៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្ត ប្រែក្លាយទៅជាភោជនីយដ្ឋាន ដើម្បីចូលរួមសកម្មភាពសេដ្ឋកិច្ចនិងផ្តល់ការងារឡើងវិញ ប៉ុន្តែត្រូវគោរពឱ្យបានម៉ឺងម៉ាត់នូវវិធាននៃក្រសួងសុខាភិបាលក្នុងការទប់ស្កាត់នូវការរីករាលដាលនៃជំងឺកូវីដ-១៩។

៦- រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ពិសេសចំពោះអ្នកអនុវត្តផ្ទាល់នៅតាមភូមិ ឃុំ សង្កាត់ទាំងអស់ទូទាំងប្រទេស ត្រូវផ្តោតការយកចិត្តទុកដាក់ខ្ពស់និងឱ្យបានច្បាស់លាស់ក្នុងការធ្វើបច្ចុប្បន្នភាពគ្រួសារក្រីក្រនិងជនងាយរងគ្រោះពិតប្រាកដដោយសារផលប៉ះពាល់នៃជំងឺកូវីដ-១៩។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានបញ្ជាក់ថានឹងចាត់វិធានការក្តៅ និងមិនមានការលើកលែងឡើយចំពោះមន្ត្រីមូលដ្ឋានដូចជាថ្នាក់ដឹកនាំភូមិ ឃុំ សង្កាត់ ដែលបន្លំឃុបឃិតគ្នាដាក់បញ្ចូលសាច់ញាតិ បងប្អូន កូនក្មួយខ្លួនឯងដែលមិនមែនជាគ្រួសារក្រីក្រនិងងាយរងគ្រោះពិតប្រាកដ ក្នុងគោលបំណងទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីផ្តល់សាច់ប្រាក់ជូនប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រនិងងាយរងគ្រោះដោយសារផលប៉ះពាល់នៃជំងឺកូវីដ-១៩នេះ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១២និង១២នាទី។

ថ្ងៃសុក្រ ១៣កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០